ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:..៤៣៩៥...PC. អក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្គត់ផ្គង់សម្ភារ និងតម្លើងខ្សែ OPGW ពីរោងចក្រវារីអគ្គិសនីគិរីរម្យ១ តាមខ្សែបញ្ជូន ១១៥ គីឡូវ៉ុល ភ្ជាប់ជាមួយខ្សែបញ្ជូន ២៣០ គីឡូវ៉ុល របស់គម្រោងខ្សែបញ្ជូន ២៣០ គីឡូវ៉ុល ភ្នំពេញ-ព្រះសីហនុ ជូននាយកដ្ឋានបញ្ជូនអគ្គិសនី

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា:អគ្គិសនីកម្ពុជានឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការអញ្ជើញចូលរួមពិគ្រោះថ្លៃស្តីពី ការផ្គត់ផ្គង់សម្ភារ និងតម្លើងខ្សែ OPGW ពីរោងចក្រវារីអគ្គិសនីគិរីរម្យ១ តាមខ្សែបញ្ជូន ១១៥ គីឡូវ៉ុល ភ្ជាប់ជាមួយខ្សែបញ្ជូន ២៣០ គីឡូវ៉ុល របស់គម្រោងខ្សែបញ្ជូន ២៣០ គីឡូវ៉ុល ភ្នំពេញ-ព្រះសីហនុ ជូននាយកដ្ឋានបញ្ជូនអគ្គិសនី។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ ក្រុមហ៊ុន / សហគ្រាស បំពេញដើម្បីចូលរួមពិគ្រោះថ្លៃ។ ឯកសារពិគ្រោះថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋានៈ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទង: 023 766007 និង Website: www.edc.com.kh ) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០២០ វេលាម៉ោង ១១ : 00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើនាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០២០ វេលាម៉ោង ១៥:១០ ។

ក្រុមហ៊ុន / សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/ សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ១៨ ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័កព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០២០
ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហង់_ឆូប

ចម្លងជូន:
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ